# សុន្ទរកថា
# ឯកឧត្តមបណ្ឌិតសភាចារ្យ អ៊ុក រ៉ាប៊ុន រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ
# ថ្លែងក្នុងពិធីបើកសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ ២០២២ និងលើក
# ទិសដៅការងារឆ្នាំ ២០២៣ របស់ក្រសួងអភិវឌ្ឍន៍ជនបទ
# ថ្ងៃអង្គារ ៣កើត ខែមាឃ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
# សណ្ឋាគារសុខាភ្នំពេញ ថ្ងៃទី២៤ ខែមករា ឆ្នាំ២០២៣

- *លោកជំទាវ ឯកឧត្តម រដ្ឋលេខាធិការ និងអនុរដ្ឋលេខាធិការ*
- *លោកជំទាវ ឯកឧត្តម លោកស្រី អស់លោក តំណាងក្រសួងស្ថាប័នរាជរដ្ឋាភិបាល*
- *លោកជំទាវ ឯកឧត្តមអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត*
- *លោកជំទាវ ឯកឧត្តម លោកស្រី អស់លោក ទីប្រឹក្សា អគ្គនាយក អគ្គាធិការ ដៃគូអភិវឌ្ឍន៍ អង្គការជាតិ អង្គការអន្តរជាតិ ប្រធាននាយកដ្ឋាន ប្រធានមន្ទីរ ប្រធានការិយាល័យ មន្ត្រីរាជការ*
- *អង្គសន្និបាត ជាទីមេត្រី !*

១. សន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ ២០២២ និង លើកទិសដៅការងារឆ្នាំ២០២៣ របស់ក្រសួងអភិវឌ្ឍន៍ជនបទ ត្រូវបានប្រារព្ធធ្វើឡើងក្នុងស្ថានភាពមួយដែលមាតុភូមិមានសុខសន្តិភាពពេញបរិបូរណ៍ រឹងមាំរួមជាមួយនឹងជោគជ័យដ៏ធំធេងដែលរាជរដ្ឋាភិបាលទើបនឹងទទួលបានថ្មីៗពុំដែលធ្លាប់មានក្នុងប្រវត្តិសាស្ត្រ ជាពិសេសនោះ គឺលទ្ធផលនៃការប្រជុំកំពូលអាស៊ាន បូករួមជាមួយនឹងការអនុវត្តនយោបាយការបរទេសឯករាជ្យផ្អែកលើច្បាប់។ ទន្ទឹមនេះ ស្ថានភាពនៃការរាតត្បាតជំងឺកូវីដ-១៩ ក៏មានការថមថយ និងត្រូវគ្រប់គ្រងបានផងដែរ តាមរយៈការដាក់ចេញនូវវិធានក្នុងការការពារ និងលើកកម្ពស់ខឿនសុខភាពប្រជាជនដ៏មានប្រសិទ្ធភាពរបស់រាជរដ្ឋាភិបាលបានទាន់ពេលវេលា ជាពិសេសគឺការចាក់វ៉ាក់សាំងស្រោចដល់ប្រជាជនគ្រប់រូបបានប្រមាណ ៩៥,២៥% នៅទូទាំងប្រទេស។ បើទោះបីជាស្ថានភាពនៃការរីករាលដាលជំងឺកូវីដ-១៩ មានភាពធូរស្រាលច្រើន ហើយប្រទេសជាតិត្រូវបានបើកឡើងវិញតាំងពីចុងឆ្នាំ២០២១ ក៏ដោយ ក៏មិនមែនមានន័យថា ជំងឺកូវីដ-១៩ បានសាបរលាប បាត់អស់ទាំងស្រុងពីពិភពលោកនោះទេ។ ដូច្នេះ យើងត្រូវតែរស់នៅតាមគន្លងប្រក្រតីភាពថ្មី ដែលត្រូវបន្តអនុវត្តគោលការណ៍ ៣ ការពារ និង ៣ កុំ ឱ្យបានខ្ជាប់ខ្ជួន។

២. ខ្ញុំសូមថ្លែងអំណរគុណដោយស្មោះ ចំពោះលោកជំទាវ ឯកឧត្តម លោកស្រី អស់លោក តំណាង ក្រសួងស្ថាប័ន តំណាងដៃគូអភិវឌ្ឍន៍ តំណាងអង្គការជាតិ និងអន្តរជាតិ ដែលបានចំណាយពេលវេលាដ៏មានតម្លៃអញ្ជើញចូលរួមក្នុងអង្គសន្និបាតនាពេលនេះ ដែលបានញ៉ាំងឱ្យបរិយាកាសនៃការប្រារព្ធអង្គសន្និបាតនាពេលនេះកាន់តែមានភាពអធិកអធម។ វត្តមានរបស់លោកជំទាវ ឯកឧត្តម

លោកស្រី អស់លោក គឺបានសបញ្ជាក់ឱ្យឃើញយ៉ាងច្បាស់អំពីសារៈសំខាន់ និងការយកចិត្តទុកដាក់ខ្ពស់ចំពោះវិស័យអភិវឌ្ឍន៍ជនបទដែលជាការងារដ៏ចាំបាច់ក្នុងការចូលរួមលើកកម្ពស់គុណភាព និងគុណតម្លៃនៃការរស់នៅរបស់ប្រជាជនជនបទតាមរយៈ ការរួមគ្នាជំរុញការអនុវត្តយុទ្ធសាស្ត្រ និង គោលនយោបាយអភិវឌ្ឍន៍ជនបទរបស់រាជរដ្ឋាភិបាល ក្នុងគោលដៅធ្វើឱ្យមានការវិវត្តជាវិជ្ជមាននូវ ស្ថានភាពសេដ្ឋកិច្ច-សង្គមកិច្ច នៅតំបន់ជនបទកម្ពុជា។

៣. ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមពាំនាំនូវការផ្ដាំផ្ញើសាកសួរសុខទុក្ខ និងពរសព្ទសាធុការ ដោយក្ដីស្រលាញ់ដ៏ជ្រាលជ្រៅ ពីសំណាក់ **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី និងសម្ដេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុន សែន ប្រធានកាកបាទក្រហមកម្ពុជា** ជូនចំពោះថ្នាក់ដឹកនាំ និងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់របស់ក្រសួងអភិវឌ្ឍន៍ជនបទ ព្រមទាំងភ្ញៀវជាតិ និងអន្តរជាតិទាំងអស់ដែលមានវត្តមាននៅក្នុងអង្គសន្និបាតនាពេលនេះ។

៤. រាជរដ្ឋាភិបាលក្រោមការដឹកនាំដ៏ឆ្លៀសវៃ និងប្រកបដោយគតិបណ្ឌិតរបស់ **សម្ដេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី** បានធ្វើឱ្យប្រទេសកម្ពុជាទទួលបាននូវការរីកចម្រើនលើគ្រប់វិស័យ និងបានអនុវត្តប្រកបដោយជោគជ័យនូវយុទ្ធសាស្ត្រចតុកោណ ដើម្បីកំណើន ការងារ សមធម៌ និងប្រសិទ្ធភាពក្នុងរយៈពេល ៣ ដំណាក់កាលរួចមកហើយ ដោយបានប្រែក្លាយប្រទេសកម្ពុជាពីប្រទេសដែលមានប្រាក់ចំណូលទាប មកជាប្រទេសដែលមានប្រាក់ចំណូលមធ្យមកម្រិតទាប។ បច្ចុប្បន្ននេះរាជរដ្ឋាភិបាល បាននិងកំពុងបន្តអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៤ បន្តទៀត សម្រាប់រាជរដ្ឋាភិបាលនីតិកាលទី៦ ឆ្នាំ២០១៨-២០២៣ ក្នុងគោលបំណងបង្កើនវឌ្ឍនភាពបន្ថែម ដើម្បីឈានទៅសម្រេចឱ្យបានចក្ខុវិស័យប្រកបដោយមហិច្ឆតា ក្នុងការប្រែក្លាយកម្ពុជាទៅជាប្រទេសដែលមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ ២០៣០ និងប្រទេសដែលមានប្រាក់ចំណូលកម្រិតខ្ពស់នៅឆ្នាំ ២០៥០។

៥. ក្នុងអាណត្តិនេះ រាជរដ្ឋាភិបាល សម្រេចបាននូវសមិទ្ធផលធំៗ និងលេចធ្លោជាច្រើន ទាំងផ្នែកសេដ្ឋកិច្ច និងសង្គមកិច្ចទាំងនៅទីក្រុង និងទីជនបទ ពិសេសបំផុតនោះគឺ ជោគជ័យយ៉ាងត្រចះត្រចង់លើការគ្រប់គ្រង និងទប់ស្កាត់ការរីករាលដាលជំងឺកូវីដ-១៩ តាមរយៈ ការដាក់ចេញនូវយុទ្ធសាស្ត្រច្បាស់លាស់ និងប្រកបដោយប្រសិទ្ធភាពដែលក្នុងនោះរួមមាន៖ ការចាក់វ៉ាក់សាំងជូនប្រជាពលរដ្ឋគ្រប់រូប និងទាន់ពេលវេលា និងវិធានការគាំទ្រដល់គ្រួសារក្រីក្រ។ កិច្ចអន្តរាគមន៍ដ៏មានប្រសិទ្ធភាពនេះបានចូលរួមកាត់បន្ថយជាអតិបរមានូវផលប៉ះពាល់ដល់ការអភិវឌ្ឍប្រទេស និងបានធ្វើឱ្យសកម្មភាពអាជីវកម្ម និងធុរកិច្ច រួមជាមួយនឹងសកម្មភាពសង្គមនានាងើបឡើងវិញ។ នាពេលថ្មីៗ រាជរដ្ឋាភិបាលក៏បានដាក់ចេញនូវយុទ្ធសាស្ត្រ ក្នុងការបន្តចាក់វ៉ាក់សាំងដែលជាដូសជំរុញជូនកុមារ និងប្រជាពលរដ្ឋពេញវ័យផងដែរ ដើម្បីបង្កើនភាពស៊ាំបន្ថែមទៀត។ ជាមួយនឹងជោគជ័យនេះ អ្នកជំនាញបានព្យាករថាកំណើនសេដ្ឋកិច្ចកម្ពុជា នឹងត្រូវងើបឡើងវិញយ៉ាងលឿនក្នុងរយៈពេលមធ្យមផងដែរ។ ជាក់ស្ដែងកំណើនសេដ្ឋកិច្ចរបស់កម្ពុជា នាឆ្នាំ២០២២ បន្តងើបឡើងក្នុងអត្រាប្រមាណ ៥,៤ ភាគរយ ហើយនៅឆ្នាំ២០២៣ នេះ រំពឹងថានឹងកើនដល់ ៦,៦%។

៦. ដោយសារមានសុខសន្តិភាព ស្ថេរភាពនយោបាយ ការអភិវឌ្ឍ និងជោគជ័យដ៏ធំធេង រួមជាមួយនឹងវិធានការដ៏មុតស្រួច និងមានប្រសិទ្ធភាព ដោយមានការគាំទ្រ និងចូលរួមដ៏សកម្មរបស់

ប្រជាជនគ្រប់មជ្ឈដ្ឋាន ក្រោមការដឹកនាំរបស់ **សម្តេចតេជោ នាយករដ្ឋមន្ត្រី** ធ្វើឱ្យយើងអាចបើកប្រទេសជាតិយើងឡើងវិញ និងអាចធ្វើជាម្ចាស់ផ្ទះក្នុងការរៀបចំកិច្ចប្រជុំធំៗ និងកិច្ចប្រជុំពាក់ព័ន្ធ នានាបានយ៉ាងរលូន និងប្រកបដោយសិមិទ្ធផលគួរឱ្យកត់សម្គាល់ ជាអាទិ៍ ការរៀបចំធ្វើជាម្ចាស់ផ្ទះនៃកិច្ចប្រជុំកំពូលអាស៊ាន និងកិច្ចប្រជុំពាក់ព័ន្ធនានា ដែលមានការចូលរួមពីថ្នាក់ដឹកនាំក្នុងតំបន់អាស៊ាន និងមេដឹកនាំធំៗលើពិភពលោក។ ភាពជោគជ័យនេះ បានសបញ្ជាក់ឱ្យឃើញយ៉ាងច្បាស់ថាប្រទេសកម្ពុជា មានសមត្ថភាពគ្រប់គ្រាន់ ក៏ដូចជាត្រូវបានទទួលស្គាល់ដោយស្មើមុខស្មើមាត់នៅលើឆាកអន្តរជាតិផងដែរ។

៧. ចំពោះវិស័យអភិវឌ្ឍន៍ជនបទ រាជរដ្ឋាភិបាល បាននិងកំពុងផ្តល់ការយកចិត្តទុកដាក់ខ្ពស់ដែលធ្វើឱ្យស្ថានភាពនៅជនបទនៅកម្ពុជាមានការរីកចម្រើនលូតលាស់គួរឱ្យកត់សម្គាល់ ហើយបាននិងកំពុងរួមចំណែកលើកកម្ពស់កម្រិតជីវភាពរស់នៅប្រជាជនជនបទយ៉ាងច្រើនផងដែរ ទោះជានៅពុំទាន់ឆ្លើយតបបានគ្រប់គ្រាន់ ទៅតាមតម្រូវការជាក់ស្តែងនៅឡើយក៏ដោយ។ ហេតុដូចនេះ ក្រសួងអភិវឌ្ឍន៍ជនបទជាសេនាធិការផ្ទាល់របស់រាជរដ្ឋាភិបាល នឹងបន្តជំរុញអនុវត្តគោលនយោបាយអភិវឌ្ឍន៍ជនបទបន្ថែមទៀត សំដៅលើកកម្ពស់គុណភាព និងគុណតម្លៃជីវិត រស់នៅរបស់ប្រជាជនជនបទប្រកបដោយបរិយាបន្ន ទាំងផ្នែកសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដើម្បីរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់រាជរដ្ឋាភិបាល។

៨. ក្រសួងអភិវឌ្ឍន៍ជនបទ បាននិងកំពុងបន្តអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជនបទ ២០១៩-២០២៣ ក្នុងគោលបំណងគោលនយោបាយចម្បងគឺ "**ការលើកកម្ពស់ គុណភាព និងគុណតម្លៃនៃជីវិតរស់នៅរបស់ប្រជាជនជនបទប្រកបដោយបរិយាប័ន្នទាំងផ្នែកសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌**" ដោយបានកំណត់យកគោលដៅជាយុទ្ធសាស្ត្រចំនួន ៤ គឺ៖ ១)ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និង គមនាគមន៍ ២) ការកែលម្អលក្ខខណ្ឌនៃការរស់នៅរបស់សហគមន៍ជនបទ ៣) ការធ្វើពិពិធកម្មសកម្មភាពសេដ្ឋកិច្ចជនបទ និង៤) ការពង្រឹងសេវាគាំទ្ររដ្ឋបាល និងកិច្ចការទូទៅ។ លទ្ធផលដែលយើងទទួលបាននៃការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជនបទ ២០១៩-២០២៣ បាននិងកំពុងរួមចំណែកយ៉ាងច្រើនក្នុងការជំរុញឱ្យមានការផ្លាស់ប្តូរជីវភាពរស់នៅរបស់ប្រជាជននៅជនបទប្រកបដោយបរិយាបន្ន ទាំងផ្នែកសេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌ និងបរិស្ថាន។ ជាក់ស្តែង ប្រជាជននៃតំបន់ជនបទ មានឱកាសប្រកបមុខរបរបន្ថែម និងផ្តល់សេវាកម្មនានាដើម្បីបង្កើនប្រាក់ចំណូលក្នុងគ្រួសារ ក្រៅពីការធ្វើស្រែចំការ។ បន្ថែមពីនេះ តំបន់ជនបទចាប់ផ្តើមមានលំនៅដ្ឋានសមរម្យ ហើយសេវាទឹកស្អាត និងអនាម័យ មានអត្រាប្រមាណជាង៨០% មានផ្លូវគមនាគមន៍កាន់តែប្រសើរឡើង មានសេវាអគ្គិសនីកាន់តែ ទូលំទូលាយ សេវាទូរគមនាគមន៍កាន់តែទំនើប និងមានប្រជាប្រិយភាពដ៏ធំធេង ដែលកត្តាទាំងនេះបាននិងកំពុងផ្លាស់ប្តូរជីវភាពរស់នៅ និងសុខភាពប្រជាជនជនបទ ឈានទៅរកជនបទដែលមានភាពស៊ីវិល័យ។

***លោកជំទាវ ឯកឧត្តម លោកស្រី អស់លោក និងអង្គសន្និបាតទាំងមូលជាទីមេត្រី !***

៩. ក្នុងការបន្តអនុវត្តនូវផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជនបទឆ្នាំ ២០១៩-២០២៣ របស់ខ្លួនសម្រាប់ឆ្នាំ ២០២២ កន្លងទៅ ក្រសួងអភិវឌ្ឍន៍ជនបទសម្រេចបាននូវលទ្ធផលសំខាន់ៗជាសារវន្តដូចតទៅ៖

**១០. ទី ១. ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត និងគមនាគមន៍៖** ក្រសួងបានយកចិត្តទុកដាក់នូវការតភ្ជាប់ហេដ្ឋារចនាសម្ព័ន្ធដល់គ្រប់ច្រកល្ហកនៃតំបន់ជនបទ ជាពិសេសតំបន់ដែលមានសក្តានុពលសេដ្ឋកិច្ចខ្ពស់។ ផ្លូវជនបទជាច្រើនរួមជាមួយនឹងសំណង់សិល្បៈការផងដែរ នៅរាជធានី និងគ្រប់ខេត្តត្រូវបានស្ថាបនា ជួសជុល និងកែលម្អ ដោយលើកកម្រិតប្រែក្លាយពីផ្លូវដីស និងផ្លូវក្រួសក្រហម ទៅជាផ្លូវក្រាលខ្សាច់ក្រួស និងក្នុងរូបភាពថ្មីគឺផ្លូវក្រាលកៅស៊ូ ឬក្រាលបេតុង ជាពិសេសក្រសួងបានយកចិត្តទុកដាក់ក្នុងការសាងសង់ផ្លូវដែលមានភាពធន់នឹងការប្រែប្រួលអាកាសធាតុ ដើម្បីធានបាននូវនិរន្តរភាព និងប្រសិទ្ធភាព ក៏ដូចជាកាត់បន្ថយការចំណាយក្នុងការថែទាំ និងជួសជុល។ ក្នុងឆ្នាំ ២០២២ ការអនុវត្តការងារស្ថាបនា កែលម្អ ជួសជុល ថែទាំ ស្ពារ និងលើកកម្រិតផ្លូវជនបទសម្រេចបានប្រវែង **៦ ០៦០ គ.ម.។**

១១. ផ្លូវជនបទបានផ្តល់អត្ថប្រយោជន៍ជាច្រើនរួមមាន៖ (១)ជាមធ្យោបាយក្នុងការធ្វើដំណើរដ៏ប្រសើរ ជួយសម្រួលដល់ការងារទំនាក់ទំនង បង្កើនឱកាសក្នុងការទទួលបានទំនិញ និងសេវាកម្មផ្សេងៗឱ្យកាន់តែប្រសើរឡើង (២) ជំរុញពិពិធកម្មនៃសកម្មភាពកសិកម្ម និងផលិតកម្ម ជួយសម្រួលដល់ការ ធ្វើពាណិជ្ជូបនីយកម្ម ដើម្បីបង្កើនការផលិតរបស់កសិករ បង្កើនចល័តភាពនៃកម្លាំងពលកម្ម សម្ភារៈ និងគ្រឿងបរិក្ខាផ្សេងៗ (៣) កាត់បន្ថយពេលវេលាក្នុងការធ្វើដំណើរ ផ្តល់ឱកាសក្នុងការបង្កើត និង បង្កើនមុខរបរបន្ថែមដល់ប្រជាជនបទដើម្បីបង្កើនប្រាក់ចំណូលផងដែរ។ ផ្លូវជនបទក៏បានផ្តល់លទ្ធភាពឱ្យប្រជាជនមានភាពងាយស្រួលក្នុងការទទួលបាន នូវសេវាសាធារណៈនានាដូចជា សេវាអប់រំ សេវាសុខាភិបាល សេវាទឹកស្អាត អនាម័យ និងសេវាទូរគមនាគមន៍ជាដើម។ និយាយជារួម ផ្លូវជនបទគឺជាឆ្អឹងខ្នងដ៏សំខាន់មិនអាចខ្វះបាន ដែលបាននិងកំពុងបំរើឱ្យការងារអភិវឌ្ឍន៍ ទាំងផ្នែកសេដ្ឋកិច្ចសង្គមកិច្ច ដែលជាមូលដ្ឋានគ្រឹះនៃការកាត់បន្ថយភាពក្រីក្រ និងវឌ្ឍនភាពសង្គមជនបទ។

១២. ទោះបីជាយ៉ាងណា ផ្លូវជនបទក៏ទទួលរងនូវផលប៉ះពាល់ដោយសារការដឹកលើសទំងន់កំណត់ និងការប្រែប្រួលអាកាសធាតុ ដែលបានបង្កឱ្យមានការខូចខាតផ្លូវជនបទជាច្រើនផងដែរ។ ទន្ទឹមនេះ កំណើននៃតម្រូវការក្នុងការប្រើប្រាស់ផ្លូវជនបទក៏មានការកើនឡើង រួមជាមួយនឹងកំណើននៃយានជំនិះរបស់បងប្អូនប្រជាពលរដ្ឋ ជាពិសេសនៅតំបន់ជនបទ ក្នុងការធ្វើដំណើរ និងដឹកជញ្ជូនកសិផលផងដែរ។ ជាការឆ្លើយតប ក្រសួងអភិវឌ្ឍន៍ជនបទ បានដាក់ចេញនូវផែនការយុទ្ធសាស្ត្រដើម្បី ពង្រឹងគុណភាព ភាពធន់ និងពន្លឿនការកសាងស្ថាបនា កែលម្អ ក៏ដូចជាការថែទាំ ផ្លូវជនបទឱ្យបានកាន់តែឆាប់រហ័ស និងមានភាពប្រសើរឡើងឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងក្នុងការប្រើប្រាស់ផ្លូវជនបទ។

**១៣. ទី ២. ការកែលម្អលក្ខខណ្ឌនៃការរស់នៅរបស់សហគមន៍ជនបទ៖** សំដៅធ្វើឱ្យប្រសើរឡើងនូវគុណភាពនៃការរស់នៅប្រកបដោយផាសុកភាព តំបន់ជនបទនឹងគ្របដណ្តប់ទៅដោយ ភូមិឃុំមានបរិស្ថានរស់នៅស្អាតបាត ទទួលបានសេវាចាំបាច់ជាច្រើនដែលជាផ្នែកមួយជួយជំរុញឱ្យមានរបៀបរស់នៅបែបទំនើប។ គិតដល់ដំណាច់ឆ្នាំ ២០២២ នេះ ប្រជាជនជនបទប្រមាណជាង ៨០% ទទួលបានសេវាបានទឹកស្អាត និងអនាម័យ។

១៤. ការងារអនាម័យសម្រាប់ឆ្នាំមុន ត្រូវបានប្រមូលផ្តុំលើការបង្កើតទម្លាប់ថ្មី ដើម្បីបំរើគោលនយោបាយពង្រឹងខឿនការពារសុខភាពរបស់រាជរដ្ឋាភិបាល ពិសេសសំដៅប្រឆាំងទល់នឹងការរាតត្បាតនៃជំងឺកូវីដ-១៩ នោះគឺ ការបំផុសប្រជាជនអោយអនុវត្ត ៣ ការពារ ដោយពាក់ម៉ាស លាងដៃ និងគម្លាតសុវត្ថិភាព ព្រមទាំង ៣ កុំ គឺ កុំចូលទៅកន្លែងបិតជិត និងប្រើម៉ាស៊ីនត្រជាក់ច្រើនពេកត្រូវរក

កន្លែងដែលមានខ្យល់ចេញចូលល្អ កុំទៅកន្លែងដែលមានមនុស្ស ច្រើនកុះករ និងកុំប៉ះពាល់គ្នាកុំចាប់ដៃគ្នា កុំគៀកស្មាគ្នា កុំអោបគ្នាជាដើម។

១៥. ទន្ទឹមនឹងនេះ ការលុបបំបាត់ទម្លាប់ចាស់ ដែលធ្លាប់តែបន្ទោបង់ពាសវាលពាសកាលបណ្តាលឱ្យពុលបរិយាកាស ខ្វះអនាម័យ អោយបែទៅរកការប្រើប្រាស់បង្គន់វិញនោះ ក៏កំពុងត្រូវបានជំរុញព្រមៗគ្នាយ៉ាងខ្លាំងក្លាដែរតាមរយៈ យន្តការនៃក្រុមការងារបច្ចេកទេស ដែលតភ្ជាប់គ្នាពីថ្នាក់ជាតិដល់ថ្នាក់ក្រោមជាតិ ដោយមានការចូលរួមអនុវត្តយ៉ាងសកម្មពីគ្រប់បណ្តាស្ថាប័នពាក់ព័ន្ធ ពីថ្នាក់ខេត្ត ថ្នាក់ស្រុកថ្នាក់ឃុំ និងមានការគាំទ្រនិងចូលរួមយ៉ាងសស្រាក់សស្រាំពីប្រជាជន និងដៃគូអភិវឌ្ឍន៍ជាច្រើនក៏បានចូលរួមកិច្ចសហប្រត្តិបត្តិការយ៉ាងភ្លៀវក្លាដែរ រហូតដល់សម្រេចបាននូវការបញ្ចប់ការបន្ទោបង់ពាសវាលពាសកាល សម្រាប់ខេត្តស្វាយរៀង ខេត្តព្រៃវែង និងខេត្តកណ្តាល ហើយ ខេត្តកំពង់ស្ពឺ ខេត្តកំពង់ឆ្នាំង និងខេត្តកែប កំពុងឈានទៅសម្រេចបាននៅក្នុងឆ្នាំ២០២៣នេះ។ បើពិនិត្យជារួមវិញ គិតមកដល់ត្រឹមឆ្នាំ ២០២២ នេះ មានស្រុកចំនួន ៣៩ ឃុំចំនួន ៤៧២ និងភូមិចំនួន ៦០២៨ ហើយ ដែលបានបញ្ចប់ការបន្ទោបង់ពាសវាលពាសកាល។

១៦. ការបញ្ចប់ការបន្ទោបង់ពាសវាលពាសកាល (Open Defecation Free ODF) គឺសំដៅទៅលើការបញ្ចប់ទាំងស្រុង នូវទម្លាប់នៃការបន្ទោបង់ក្រៅបង្គន់ ដូចជា ការបន្ទោបង់តាមគុម្ពោតព្រៃ តាមទឹក តាមទីវាលជាដើម។ យើងបានដឹងហើយថា ទម្លាប់នៃការរបន្ទោបង់ខាងក្រៅទាំងនេះ បានធ្វើឱ្យមានផលប៉ះពាល់យ៉ាងខ្លាំងដល់សុខភាព បរិស្ថាននៃការរស់នៅ សកម្មភាពទេសចរណ៍ និង សេចក្តីថ្លៃថ្នូរនៃសង្គមជាតិយើង។ ដូច្នេះ ODF គឺពិតជាមានសារសំខាន់ណាស់ ក្នុងការចូលរួមចំណែកលើកកម្ពស់ខឿនសុខភាពប្រជាជន អាហារូបត្ថម្ភ ជាពិសេសលើកកម្ពស់សុខភាពកុមារ និងស្ត្រី ធ្វើឱ្យសហគមន៍ជនបទមានបរិស្ថានល្អទាក់ទាញភ្ញៀវទេសចរ និងធ្វើឱ្យសហគមន៍ជនបទមានភាពស៊ីវិល័យស្របតាមនិន្នាការនៃការអភិវឌ្ឍរបស់ប្រទេសយើង។

**១៧. ទី ៣. ពិពិធកម្មសកម្មភាពសេដ្ឋកិច្ចជនបទ៖** ក្នុងន័យបង្កើតការងារ មុខរបរ សហគ្រិនភាព និងសកម្មភាពសេដ្ឋកិច្ចឱ្យមានរូបភាពចម្រុះដោយគិតតាំងពីរបរកសិកម្ម និងមិនមែនកសិកម្មនៅតាមសហគមន៍ជនបទ ដើម្បីចូលរួមដោះស្រាយបញ្ហាជីវភាពរស់នៅប្រចាំថ្ងៃ បង្កើនប្រាក់ចំណូលគ្រួសារនីមួយៗនៅជនបទ។ កម្មវិធីការធ្វើពិពិធកម្មសកម្មភាពសេដ្ឋកិច្ចជនបទ សម្រេចបាននូវវឌ្ឍនភាពជាច្រើនតាមរយៈការបង្កើតមុខរបរ សហគ្រិនភាព និងសកម្មភាពសេដ្ឋកិច្ចនានា។ កត្តាទាំងអស់នេះ បាននិងកំពុងចូលរួមចំណែកលើកកម្ពស់ជីវភាពរស់នៅ ក៏ដូចជាកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន ដែលភាគច្រើនរស់នៅទីជនបទ។ បន្ថែមពីលើនេះ សកម្មភាពនានាដែលរួមមាន៖ ការបណ្តុះបណ្តាល ជំនាញវិជ្ជាជីវៈ ខាងកសិកម្ម សិប្បកម្ម សេវាកម្មតូចតាច និងមុខរបរដទៃទៀត បង្កឱ្យគ្រួសារនីមួយៗ ទទួលបាននូវប្រាក់ចំណូលបន្ថែម និងបង្កើតបាននូវភាពសុខដុមរមនាក្នុងសង្គមជនបទ កាត់បន្ថយការធ្វើចំណាកស្រុកទៅកាន់ទីក្រុង ឬឆ្លងដែនដោយប្រថុយប្រថានទៅប្រទេសដទៃ។

**១៨. ទី ៤. ការងារពង្រឹងស្ថាប័ន អភិវឌ្ឍន៍សមត្ថភាពនិងធនធានមនុស្ស៖** ដើម្បីធានាប្រសិទ្ធភាពនៃការគ្រប់គ្រង ក្រសួងគាំទ្រដល់កម្មវិធីអភិវឌ្ឍធនធានមនុស្ស និងអភិបាលកិច្ចល្អ ការអភិវឌ្ឍប្រកបដោយនិរន្តរភាពទាំងនៅថ្នាក់ជាតិ និងនៅថ្នាក់ក្រោមជាតិសំដៅរួមចំណែកក្នុងការអនុវត្តកម្មវិធីកំណែទម្រង់រដ្ឋបាលសាធារណៈ កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដោយប្រើប្រាស់

យន្តការនៃការអនុវត្តថវិកា តាមរយៈការពង្រឹងការអនុវត្តថវិកាកម្មវិធីកាន់តែស៊ីជម្រៅ និងអនុវត្តផែនការថវិកាពត៌មានសមិទ្ធិកម្មប្រកបដោយការទទួលខុសត្រូវ កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ដោយបានផ្ទេរមុខងារ និងភារកិច្ចមួយចំនួនដល់ថ្នាក់ក្រោមជាតិ និងកំណែទម្រង់ដ៏ទៃទៀតឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់។ សមត្ថភាពរបស់ស្ថាប័នរួម នឹងសមត្ថភាពរបស់មន្ត្រីរាជការមានការរីកចម្រើនគួរឱ្យកត់សម្គាល់ តាមរយៈការបណ្តុះបណ្តាល និងការពង្រឹងសមត្ថភាពជំនាញមូលដ្ឋាន។ ការរៀបចំ និងការគ្រប់គ្រងផែនការ ក៏ដូចជាការប្រើប្រាស់ថវិកាត្រូវបានរៀបចំប្រកបដោយគុណភាព និងកាន់តែប្រសើរឡើង និងប្រព្រឹត្តទៅតាមគោលការណ៍ណែនាំ និងបទដ្ឋានគតិយុត្តិនានាដែលបានដាក់ចេញដោយរាជរដ្ឋាភិបាល។ មន្ត្រីរបស់ក្រសួងក៏ត្រូវបានជ្រើសរើស ឱ្យចូលរួមក្នុងវគ្គបណ្តុះបណ្តាលនៅសាលាភូមិន្ទរដ្ឋបាល ដើម្បីពង្រឹងសមត្ថភាពផងដែរ។ ជាមួយគ្នានេះផងដែរ ក្រសួងបានរៀបចំក្រុមការងាររដ្ឋាភិបាលឌីជីថល បច្ចេកវិទ្យាពត៌មានគមនាគមន៍ ដើម្បីឆ្លើយតបទៅនឹងការវិវត្តន៍នៃបច្ចេកវិទ្យា និងទំនើបកម្ម ៤.០។

១៩. ជារួម ក្រសួងអភិវឌ្ឍន៍ជនបទដែលជាសេនាធិការមួយដ៏សំខាន់របស់រាជរដ្ឋាភិបាលលើវិស័យអភិវឌ្ឍន៍ជនបទ បាននិងកំពុងចូលរួមចំណែកយ៉ាងសកម្មក្នុងការអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់ ទី៤ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ២០១៩-២០២៣ ក៏ដូចជាក្របខណ្ឌគោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា ឆ្នាំ ២០១៦-២០៣០ និងទស្សនៈវិស័យរបស់រាជរដ្ឋាភិបាលឈានទៅសម្រេចឱ្យបាននូវគោលដៅប្រែក្លាយប្រទេសកម្ពុជា ជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់នាឆ្នាំ ២០៣០ និងជាប្រទេសមានចំណូលខ្ពស់នាឆ្នាំ ២០៥០ ក្នុងការកែលម្អ និងលើកកម្ពស់ស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌របស់ប្រជាជនជនបទ កាត់បន្ថយភាពក្រីក្រ និងភាពខុសគ្នារវាងអ្នកជនបទ និងអ្នកទីក្រុង ដើម្បីឈានទៅរកការអភិវឌ្ឍប្រកបដោយចីរភាព បរិយាបន្ន និងស៊ីវិល័យ តាមរយៈការលើកកម្ពស់ជីវភាពរស់នៅ និងការកែលម្អលក្ខខណ្ឌនៃការរស់នៅរបស់សហគមន៍ជនបទ។

### *លោកជំទាវ ឯកឧត្តម លោកស្រី អស់លោក និងអង្គសន្និបាតទាំងមូលជាទីមេត្រី !*

២០. ដោយឆ្នាំ ២០២៣ ជាឆ្នាំចុងក្រោយនៃរាជរដ្ឋាភិបាលនីតិកាលទី ៦ ជាមួយនឹងការត្រួតពិនិត្យ និងវាយតម្លៃនូវវឌ្ឍនភាពការងារប្រចាំឆ្នាំ ក្រសួងអភិវឌ្ឍន៍ជនបទ នឹងបន្តខិតខំយ៉ាងខ្លាំងក្លា និងសម្រួចគោលដៅរបស់ខ្លួនបន្ថែមទៀត ដើម្បីឈានទៅសម្រេចតាមតាមគោលដៅដែលបានកំណត់ រួមមាន៖ (១). បន្តបង្កើនការតភ្ជាប់ហេដ្ឋារចនាសម្ព័ន្ធផ្លូវជនបទ ដោយមានភាពធន់នឹងការប្រែប្រួលអាកាសធាតុ ដើម្បីធានាប្រសិទ្ធភាពនៃការប្រើប្រាស់ផ្លូវជនបទបានយូរអង្វែង និងដើម្បីជំរុញដល់ការអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌នៅតំបន់ជនបទ (២). បន្តកែលម្អលក្ខខណ្ឌនៃការរស់នៅរបស់សហគមន៍ជនបទ ដោយជំរុញការផ្តល់សេវាទឹកស្អាត និងអនាម័យ ដើម្បីឈានទៅសម្រេចបានគោលដៅនៃអត្រាគ្របដណ្តប់សេវាទឹកស្អាតនិងអនាម័យជនបទ ៩០% នៅឆ្នាំ២០២៣ និង ១០០% នៅឆ្នាំ២០២៥ (៣). ពង្រីកសកម្មភាពពិពិធកម្មសកម្មភាពសេដ្ឋកិច្ចជនបទ សំដៅធានាជំរុញកំណើនសេដ្ឋកិច្ចតាមគ្រួសារ នៅតំបន់ជនបទ ធ្វើឲ្យសហគមន៍មានបំណិនជីវិត អាចបង្កើតជំនាញផ្ទាល់ខ្លួន បង្កើតមុខរបរនិងបង្កើនប្រាក់ចំណូល (៤). ពង្រឹងសមត្ថភាព ក្នុងការផ្តល់សេវាជូនប្រជាជននៅជនបទ តាមរយៈ ការរៀបចំគោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព ចូលរួមអនុវត្តកម្មវិធី

កំណែទម្រង់នានា និងបន្តពង្រឹងកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍នានា បណ្តាប្រទេសអាស៊ាន អង្គការមិនមែនរដ្ឋាភិបាល។

២១. ឯកឧត្តមបណ្ឌិត **សួស គន់** រដ្ឋលេខាធិការប្រចាំការនៃក្រសួងអភិវឌ្ឍន៍ជនបទនឹងរាយការណ៍សង្ខេបជូនអង្គសន្និបាតអំពីលទ្ធផលការងារឆ្នាំ ២០២២ និងទិសដៅការងារឆ្នាំ ២០២៣ ដើម្បី ជាមូលដ្ឋានសម្រាប់ការសិក្សាស្វែងយល់ហើយយើងក៏មានរបាយការណ៍លម្អិតបូកសរុបរួម និងរបាយការណ៍ តាមកម្មវិធីនីមួយៗ សម្រាប់ការពិនិត្យវាយតម្លៃ និងពិភាក្សាស្វែងរកចំណុចខ្លាំង និងចំណុចខ្សោយ ដើម្បីកែលម្អ និងបំពេញបន្ថែមជាយថាហេតុ។

២២. ឆ្លៀតក្នុងឱកាសនេះ ក្នុងនាមថ្នាក់ដឹកនាំ និងមន្ត្រីរាជការក្រសួងអភិវឌ្ឍន៍ជនបទ ខ្ញុំសូមសម្តែងនូវកតញ្ញូតាធម៌យ៉ាងជ្រាលជ្រៅជូនចំពោះ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី** ដែលតែងតែផ្តល់ការដឹកនាំប្រកបដោយភាពឆ្លៀសវៃ និងគតិបណ្ឌិត និងសូមសម្តែងការកោតសរសើរ និងថ្លែងអំណរអរគុណដោយស្មោះជូនចំពោះថ្នាក់ដឹកនាំ និងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ ដែលបាននិងកំពុងបំពេញភារកិច្ចនៅក្រសួង និងនៅរាជធានីខេត្ត ចំពោះការលះបង់ទាំងកម្លាំងកាយចិត្តខិតខំអនុវត្តន៍ការងារយ៉ាងខ្ជាប់ខ្ជួន ធ្វើឱ្យសម្រេចបាននូវសមិទ្ធផលជាច្រើនក្នុងវិស័យអភិវឌ្ឍន៍ជនបទប្រកបដោយស្មារតីសាមគ្គីភាព និងការទទួលខុសត្រូវ។ ខ្ញុំសូមអរគុណយ៉ាងជ្រាលជ្រៅចំពោះក្រសួងស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ អង្គការជាតិ និងអន្តរជាតិ ប្រជាជន និងសប្បុរសជន ដែលបានរួមចំណែកឧបត្ថម្ភគាំទ្រទាំងស្មារតីសម្ភារៈបច្ចេកទេស និងថវិកាដល់បុព្វហេតុអភិវឌ្ឍជនបទនៅកម្ពុជា។

២៣. ជាទីបញ្ចប់ ខ្ញុំសូមថ្លែងអំណរគុណសារជាថ្មីម្តងទៀតដល់ **លោកជំទាវ ឯកឧត្តម លោកស្រី អស់លោក សមាជិក សមាជិកា** អង្គសន្និបាតទាំងមូល ដែលបានអញ្ជើញចូលរួមក្នុងសន្និបាតបូកសរុបការងារឆ្នាំ២០២២ និងលើកទិសដៅការងារឆ្នាំ២០២៣ របស់ក្រសួងអភិវឌ្ឍន៍ជនបទ នាពេលនេះ។ ខ្ញុំសូមជូនពរ **លោកជំទាវ ឯកឧត្តម លោកស្រី អស់លោក ទាំងអស់** បានប្រកបដោយ សុខភាពល្អបរិបូរណ៍ទទួលបានជោគជ័យគ្រប់ភារកិច្ចរៀងៗខ្លួន និងមានសុភមង្គលក្នុងគ្រួសារ។

*ខ្ញុំសូមប្រកាសបើកសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០២២ និងលើកទិសដៅការងារឆ្នាំ២០២៣ របស់ក្រសួងអភិវឌ្ឍន៍ជនបទចាប់ពីពេលនេះតទៅ ៕*

**សូមអរគុណ** !